

# ច្បាប់ស្តីពីការសង្គ្រោះពលរដ្ឋអាមេរិក (ARPA)

# ផិដ្ឋភាពរួមនៃការផ្តល់មូលនិធិជំនួយទូទៅ

# និង

# ការណែនាំអំពីការដាក់ពាក្យសុំ

# មាតិការឿង


សេចក្តីណែនាំ និងសារពីអ្នកគ្រប់គ្រងទីក្រុង ..... 3

អំពីច្បាប់ស្តីពីការសង្គ្រោះពលរដ្ឋអាមេរិក (ARPA) ..... 5

អំពីផែនការស្តារឡើងវិញរបស់ទីក្រុងឡូវែល ..... 6

ប្រភេទនៃថវិកាជំនួយរបស់ច្បាប់ ARPA ដែលមានស្រាប់តាមរយៈសាលាក្រុងឡូវែល ..... 8

ទិដ្ឋភាពនៃដំណើរការនៃមូលនិធិជំនួយនៃច្បាប់ ARPA ..... 10

- ព័ត៌មានទូទៅអំពីដំណើរការនេះ ..... 10
- សិទ្ធិដាក់ពាក្យសុំ – តើនរណាអាចដាក់ពាក្យសុំមូលនិធិជំនួយនេះបាន? ..... 10
- ពេលវេលា – តើអង្កាល់ទើបចាប់ផ្តើមទទួលពាក្យសុំមូលនិធិជំនួយនៃច្បាប់ ARPA នេះ? ..... 10
- ការត្រៀមរៀបចំ – តើខ្ញុំត្រៀមខ្លួនយ៉ាងដូចម្តេចដើម្បីដាក់ពាក្យសុំនេះ? ..... 11
- ការដាក់ពាក្យ - បំពេញពាក្យសុំថវិកាជំនួយនៃច្បាប់ ARPA និងដាក់វាដើម្បីត្រួតពិនិត្យ ..... 11
- ដំណើរការ - តើសាលាក្រុងនឹងពិនិត្យពាក្យសុំថវិកាជំនួយនៃច្បាប់ ARPA របស់លោកអ្នកយ៉ាងដូចម្តេច? ..... 12
- ការផ្តល់ថវិកាជំនួយ - តើសាលាក្រុងនឹងផ្តល់ថវិកាជំនួយទៅតាមសំណើនោះយ៉ាងដូចម្តេច? ..... 12
- ការផ្តល់មូលនិធិ - តើសាលាក្រុងនឹងផ្តល់មូលនិធិដល់គម្រោងដេញថ្លៃបានយ៉ាងដូចម្តេច? ..... 13

តើខ្ញុំអាចរកព័ត៌មានបន្ថែមបានយ៉ាងដូចម្តេច? ..... 14

**សាលាក្រុងឡូវែល**

*ការិយាល័យអ្នកគ្រប់គ្រងទីក្រុង*

375 Merrimack Street • Lowell, MA 01852

P: 978.674-4400 • F: 978.970.4007 • www.lowellma.gov

**Thomas A. Golden, Jr.**

***អ្នកគ្រប់គ្រងទីក្រុង***

## សេចក្ដីណែនាំ និងសារពីអ្នកគ្រប់គ្រងទីក្រុង

ច្បាប់ស្ដីពីការសង្គ្រោះពលរដ្ឋអាមេរិក (ARPA)ត្រូវបានចុះហត្ថលេខាឲ្យចេញជាច្បាប់ កាលពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១។ ច្បាប់នេះត្រូវបានបង្កើតឡើង ក្នុងស្ថានភាពនៃការរីករាលដាលនៃមេរោគកូរ៉ូណា និងមូលនិធិស្តារឡើងវិញសម្រាប់ឆ្នាំសារពើពន្ធមូលដ្ឋាន ដើម្បីបញ្ចេញកញ្ចប់ថវិកាចំនួន ៣៥០ ពាន់លានដុល្លារ ដើម្បីផ្ដល់ជូនរដ្ឋ ដែនដី ក្រុង តំបន់ និងរដ្ឋាភិបាលកុលសម្ព័ន្ធ ដែលត្រូវការជំនួយជាចាំបាច់។ ថវិកានេះគឺបន្ថែមទៅលើថវិកាដែលមានពីមុន ដែលត្រូវបានសម្រាំងទុកក្នុងច្បាប់ស្ដីពីជំនួយផ្នែកមេរោគកូរ៉ូណា ការសម្រាលបន្ទុក និងសន្តិសុខសេដ្ឋកិច្ច (CARES) ដែលមានទឹកប្រាក់ជាង ៧៥ លានដុល្លារ ដែលមានសម្រាំងទុកសម្រាប់ទីក្រុងឡូវែល ដើម្បីជួយយើងក្នុងគម្រោងស្តារទីក្រុងឡើងវិញពីការរីករាលដាលនៃជំងឺជាសាកល។

ចាប់តាំងពីប្រកាស រដ្ឋបាលក្រុងឡូវែលបានដុតដៃដុតជើង ដាក់ចេញកិច្ចការ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលមិនធ្លាប់មាន ក្នុងការបញ្ចេញថវិកាទាំងនេះ ទៅដល់សហគមន៍។ កិច្ចខិតខំប្រឹងប្រែង និងទំហំការងារដែលក្រុមរបស់ខ្ញុំបានធ្វើ ក្នុងការវិនិយោគផ្នែកត្រៀមរៀបចំសម្រាប់ការអនុវត្តគម្រោងផ្ដល់ថវិកាជំនួយនេះ ឲ្យមាននិរន្តរភាព។ ការយល់ដឹងអំពីវិធាន និងបទប្បញ្ញត្តិជាតិ ដែលចងភ្ជាប់ទៅនឹងមូលនិធិទាំងនេះ និងការបង្កើត និងដាក់ចេញជាយន្តការ ដើម្បីកាត់បន្ថយហានីភ័យចំពោះសាលាក្រុង ក្នុងពេលធានាឲ្យបានការអនុវត្តតាម និងការត្រួតពិនិត្យមធ្យោបាយដើម្បីធានាឲ្យមានតម្លាភាព និងការកំណត់ថាតើនរណានឹងគ្រប់គ្រងមូលនិធិនេះ និងគ្រប់គ្រងដោយរបៀបណា និងការវាយតម្លៃសេចក្ដីត្រូវការចាំបាច់របស់សហគមន៍ ព្រមទាំងការបង្កើតចំណុចអាទិភាពសម្រាប់ និងការបង្កើតដំណើរការដាក់ពាក្យសុំ/វាយតម្លៃ/ផ្ដល់ថវិកាជំនួយ/រាយការណ៍ និងបង្ហើយកិច្ចការអំពីរបៀបដែលមូលនិធិនោះត្រូវបញ្ចេញដោយរបៀបណា គឺត្រូវការពេលវេលា និងធនធានច្រើន។

ដើម្បីស្វាគមន៍ឱកាសវិនិយោគដ៏សំខាន់ និងក្នុងរបត់ដែលមានការប្រែប្រួលដ៏គួរឲ្យកត់សម្គាល់តាមរយៈសាលាក្រុងឡូវែលនេះ យើងបានផ្ដោតលើការប្រមូលមតិសាធារណជន ពីសហគមន៍ ក្នុងពេលដែលយើងកំណត់អំពីរបៀបចាប់ផ្ដើមរកដំណោះស្រាយ ទៅនឹងបញ្ហាប្រឈមរយៈពេលយូរអង្វែង។ យើងក៏ផ្ដោតផងដែរ ទៅលើគំនិតអន្តរនាយកដ្ឋាន ដែលដោះស្រាយបញ្ហាសមធម៌ ការងារធ្វើ និងសុខភាពនៅទូទាំងទីក្រុង ក្នុងពេលដែលយើងវាយតម្លៃអំពីមធ្យោបាយ ក្នុងការប្រើប្រាស់ធនធានបន្ថែមរបស់រដ្ឋ និងឯកជន ដើម្បីផ្ដល់អាទិភាពផ្នែកនិរន្តរភាពហិរញ្ញវត្ថុ ដែលហួសពីច្បាប់ស្ដីពីការសង្គ្រោះពលរដ្ឋអាមេរិក។

ដោយមានការជួយគាំទ្រជាបន្តបន្ទាប់របស់ក្រុមប្រឹក្សាក្រុង រដ្ឋបាលរបស់យើងខ្ញុំ និងខ្ញុំបានប្តេជ្ញាចិត្តធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធនៅក្នុងសហគមន៍ និងពលរដ្ឋសហគមន៍ ស្របពេលដែលយើងកំពុងខិតខំត្រួសត្រាយផ្លូវទៅរកការស្តារឡើងវិញ ដោយផ្តោតលើសុខុមាលភាពរបស់គ្រួសារ ការកែលម្អភូមិ និងការបង្កើតបរិស្ថានដែលអំណោយផលដល់វិបុលភាព និងការរីកចម្រើនក្នុងអាជីវកម្មសហគមន៍របស់យើង ដែលក្នុងពេលជាមួយគ្នានេះ យើងលើកទឹកចិត្តឲ្យមានការវិនិយោគថ្មីៗទៅលើអនាគតរបស់យើង។

សូមអរគុណលោកអ្នក ដែលបានជួយជ្រោមជ្រែងយើងជាបន្តបន្ទាប់ និងការអត់ធ្មត់ ក្នុងពេលដែលយើងបន្តកិច្ចខិតខំប្រឹងប្រែងស្តារទីក្រុងឡូវែលរបស់យើងទាំងមូល ឡើងវិញនេះ។

ដោយសេចក្តីគោរព!

Thomas A. Golden Jr.

## អំពីច្បាប់ស្តីពីការសង្គ្រោះពលរដ្ឋអាមេរិក (ARPA)

ច្បាប់ស្តីពីការសង្គ្រោះពលរដ្ឋអាមេរិក(ARPA)នេះ ត្រូវបានបង្កើតឡើង ក្នុងស្ថានភាពនៃការរីករាលដាលនៃមេរោគកូវីដ និងមូលនិធិស្តារឡើងវិញសម្រាប់ឆ្នាំសារពើពន្ធមូលដ្ឋាន ដើម្បីបញ្ចេញកញ្ចប់ថវិកាចំនួន ៣៥០ ពាន់លានដុល្លារ ដើម្បីផ្តល់ជូនរដ្ឋ ដែនដី ក្រុង តំបន់ និងរដ្ឋាភិបាលកុលសម្ព័ន្ធ ដែលត្រូវការជំនួយជាចាំបាច់ ដែលត្រូវបំពេញគោលដៅសំខាន់ៗដូចខាងក្រោម៖

- ទ្រទ្រង់ដល់គម្រោងឆ្លើយតបទៅនឹងភាពបន្ទាន់នៃជំងឺកូវីដ-១៩ ដើម្បីបន្តកាត់បន្ថយការឆ្លងរាលដាលនៃមេរោគនេះ និងគ្រប់គ្រងការឆ្លងរាលដាលជាសាកលនេះឲ្យបាន។
- ជំនួសប្រាក់ចំណូលដែលបាត់បង់ សម្រាប់អ្នកទទួលបានថវិកាជំនួយដែលគ្រប់លក្ខខណ្ឌ ក្នុងការពង្រឹងការទ្រទ្រង់សម្រាប់សេវាសាធារណៈដែលសំខាន់ៗ និងជួយរក្សាការងារធ្វើ។
- ទ្រទ្រង់ស្ថេរភាពសេដ្ឋកិច្ចបន្ទាន់ សម្រាប់គ្រួសារ និងអាជីវកម្ម។
- ដោះស្រាយបញ្ហាប្រឈមផ្នែកសុខភាពសាធារណៈ និងសេដ្ឋកិច្ចជាប្រព័ន្ធ ដែលជាដើមហេតុនៃផលប៉ះពាល់មិនស្មើភាពគ្នានៃការរីករាលដាលជាសាកលនៃជំងឺទៅលើប្រជាពលរដ្ឋជាក់លាក់មួយចំនួន។

តាមរតនាគារអាមេរិក ការចំណាយដែលត្រឹមត្រូវ គឺត្រូវតែ (១) ជាការចំណាយដែលបានកើតមានឡើងរវាងថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១ និងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៦ (ដោយថ្លៃចំណាយជាក់លាក់ ត្រូវស្ថិតក្រោមកាលៈទេសៈពិសេស ដែលអាចសមស្របដែរទោះជាត្រូវធាក់ថយរហូតដល់ខែ មីនា ឆ្នាំ ២០២០) និង (២) ត្រូវស្ថិតក្នុងផ្នែកណាមួយខាងក្រោម៖

- *ទ្រទ្រង់ការឆ្លើយផ្នែកសុខភាពសាធារណៈ ទៅនឹងការឆ្លងរាលដាលជាសាកលនៃជំងឺកូវីដ* ផ្តល់ថវិកសម្រាប់គម្រោងកាត់បន្ថយជំងឺកូវីដ-១៩ ការចំណាយផ្នែកវេជ្ជសាស្ត្រ ការថែទាំសុខភាពផ្នែកផ្លូវចិត្ត និងបុគ្គលិកសុខាភិបាលសាធារណៈជាក់លាក់ និងសុវត្ថិភាព។
- *ដោះស្រាយផលប៉ះពាល់ជាអវិជ្ជមានផ្នែកសេដ្ឋកិច្ច ពីការឆ្លងរាលដាលជាសាកលនៃជំងឺកូវីដ* ឆ្លើយតបទៅនឹងព្យសនកម្មផ្នែកសេដ្ឋកិច្ចទៅលើកម្មករ គ្រួសារ អាជីវកម្មដែលរងផលប៉ះពាល់ និងវិស័យសាធារណៈ។

- *កែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងទឹកស្អុយ*
  ដាក់ទុនវិនិយោគចាំបាច់ ដើម្បីកែលម្អសេវាទឹកស្អាតសម្រាប់បរិភោគ និងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹកកង្វក់ និងទឹកភ្លៀង។

- *ផ្តល់ធនលាភសម្រាប់បង់ជូនកម្មករដែលត្រូវធ្វើការជាចាំបាច់*
  ផ្តល់ការទ្រទ្រង់បន្ថែម ទៅដល់អ្នកដែលមាន និងអ្នកដែលប្រឈមនឹងហានិភ័យខ្ពស់បំផុតផ្នែកសុខភាព ដោយសារតែសេវាដែលពួកគាត់ផ្តល់ឲ្យ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដែលប្រឈមខ្ពស់នឹងគ្រោះថ្នាក់។

- *ដាក់ទុនវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធទូទៅ*
  ដាក់ទុកវិនិយោគជាចាំបាច់ ដើម្បីផ្តល់ឲ្យតំបន់ដែលមិនដែលទទួលបានសេវា ឬដែលគេមើលរម្លង ដើម្បីឲ្យមានសេវាទូទំទូលាយសម្រាប់ពលរដ្ឋទាំងនោះ។

- *ជំនួសប្រាក់ចំណូលវិស័យសាធារណៈដែលបាត់បង់*
  ប្រើប្រាស់មូលនិធិ ដើម្បីផ្តល់សេវារដ្ឋាភិបាល ដើម្បីកាត់បន្ថយការថយចុះប្រាក់ចំណូលដោយសារតែការរីករាលដាលជាសាកលនៃជំងឺកូវីដ។

## អំពីផែនការស្តារឡើងវិញរបស់សាលាក្រុងឡូវែល

សាលាក្រុងឡូវែលទទួលបានប្រាក់ជាង ៧៥ លានដុល្លារ ពីកញ្ចប់ថវិកា SLRFR ដើម្បីជួយសាលាក្រុងតាមផែនការស្តារទីក្រុងឡុងឡើងវិញរបស់ខ្លួន។ ក្រុមការងារ ARPA របស់ក្រុងឡូវែល បំពេញមុខងារនៅទូទាំងនាយកដ្ឋានហិរញ្ញវត្ថុនៃការិយាល័យអ្នកគ្រប់គ្រងទីក្រុង ដោយទទួលខុសត្រូវក្នុងការចាត់ចែងកញ្ចប់ថវិកា ARPA សម្រាប់ក្រុង និងបានផ្តោតលើការធ្វើយ៉ាងណាធានាឲ្យបានការប្រើប្រាស់កញ្ចប់ថវិកា ARPA ឲ្យបានសមស្រប និងប្រមូលទិន្នន័យអំពីសេចក្តីត្រូវការចាំបាច់របស់សហគមន៍ និងគម្រោងដែលអាចមានក្នុងកិច្ចខិតខំជួយណែនាំអ្នកគ្រប់គ្រងទីក្រុង និងក្រុមប្រឹក្សាក្រុង ក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។

ផែនការស្តារទីក្រុងឡើងវិញរបស់សាលាក្រុងឡូវែលនេះ មានបញ្ចូលទាំងការប្តេជ្ញាចិត្ត ធានាឲ្យមានតម្លាភាព និងដំណើរការប្រកបដោយការទទួលខុសត្រូវ ក្នុងកិច្ចខិតខំរបស់យើង ដើម្បីផ្តល់មូលនិធិដល់គម្រោងដែលបំពេញគ្រប់លក្ខខណ្ឌ និងដែលមានផលប្រយោជន៍ ដោយប្រើប្រាស់កញ្ចប់ថវិកា ARPA ដែលត្រូវបានបែងចែករបស់យើង។ នៅពេលនេះ ផ្នែកសំខាន់ៗនៅក្នុងសហគមន៍យើង ដូចមានរៀបរាប់ខាងក្រោមនេះ ត្រូវបានកំណត់ ថាជាផ្នែកដែលត្រូវប្រើប្រាស់កញ្ចប់ថវិកាជំនួយនេះ៖

- ***កម្មវិធីបានផលដល់សហគមន៍។*** តាមរយៈច្បាប់ ARPA សាលាក្រុងនឹងវិនិយោគក្នុងកម្មវិធីផ្តល់ផលដល់សង្គមជាច្រើនខុសៗគ្នា ដើម្បីសម្រេចការប្តេជ្ញា និងការវិនិយោគទៅក្នុងផ្នែកសំខាន់ៗដូចជាអប់រំ/បណ្តុះបណ្តាល សុខភាពសាធារណៈ សមធម៌សង្គម/សេដ្ឋកិច្ច និងការយកចិត្តទុកដាក់លើពលរដ្ឋវ័យចំណាស់។

- ***ផែនការផ្លាស់ប្តូរគ្រឿងចក្រនៅនាយកដ្ឋានពន្លត់អគ្គីភ័យឡូវែល។*** នាយកដ្ឋានពន្លត់អគ្គីភ័យរបស់ទីក្រុងឡូវែល មានរថយន្តសរុប ៤៣ គ្រឿង។ ក្នុងនោះឧបករណ៍មួយចំនួនធំ ត្រូវបានប្រើប្រាស់សម្រាប់រឿងគ្រប់យ៉ាង តាំងពីការឆ្លើយតបទៅនឹងការបណ្តុះបណ្តាល និងមុខងារបុគ្គលិក។ គ្រឿងទាំងនេះមានអាយុកាលជាមធ្យមពី ១៥-១៦ ឆ្នាំ។ យានយន្តដែលមានសព្វថ្ងៃនេះ គឺស្ថិតក្នុងស្ថានភាពមានបញ្ហា។ មូលនិធិនៃកញ្ចប់ថវិកា ARPA នឹងអនុញ្ញាតឲ្យសាលាក្រុងផ្លាស់ប្តូរគ្រឿងចក្រចាស់ៗទាំងនេះស្ទើរតែទាំងស្រុង។

- ***ផែនការកែលម្អភូមិឋានឡូវែល។*** ផែនការកែលម្អភូមិឋានពីកញ្ចប់ថវិកា ARPA នឹងរួមបញ្ចូលការផ្តល់មូលនិធិដោយផ្ទាល់ សម្រាប់គម្រោងឧទ្យានដែលស័ក្តិសមនឹងទទួលបានថវិកា គម្រោងហេដ្ឋារចនា សម្ព័ន្ធទឹកស្អាត និងទឹកស្អុយ និងការកែលម្អតំបន់អាជីវកម្មក្នុងសង្កាត់ នៅទូទាំងទីក្រុងឡូវែល ដោយផ្តោតលើតំបន់ក្រីក្រដែលរកឃើញក្នុងជំរឿន។

- ***ការកែលម្អអគារក្រុង។*** ការដាក់គោលដៅមូលនិធិសម្រាប់អគារសាលា ព្រមទាំងអគារក្រុងសម្រាប់គម្រោងកែលម្អដែលស័ក្តិសមនឹងបានថវិកាជំនួយ (ឧទាហរណ៍ HVAC ការកែលម្អឲ្យត្រូវតាមបទដ្ឋានច្បាប់អំពីជនពិការ ។ល។)។

- ***ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងទឹកកង្វក់។*** សាលាក្រុងនឹងពន្លឿនកិច្ចខិតខំរបស់ខ្លួន ដើម្បីបំពេញគម្រោងញែកទឹកស្អុយ នៅអនុតំបន់ the Humphrey's Brook / Billing Brook អនុតំបន់ Tilden Street និងតំបន់ដែលកំណត់ដទៃទៀត ដើម្បីកាត់បន្ថយ CSOs។ ការវិនិយោគនឹងត្រូវធ្វើផងដែរ ក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងទិញគ្រឿងចក្រធុនធ្ងន់ ដើម្បីរក្សាប្រព័ន្ធទឹកស្អាត និងទឹកស្អុយឲ្យបានល្អប្រសើរជាងនេះ។

- ***ការទ្រទ្រង់អង្គការមិនរកប្រាក់កម្រៃ។*** ដោយធ្វើការជាដៃគូគ្នាជាមួយទីភ្នាក់ងារមិនរកប្រាក់កម្រៃដែលមានភាពរស់រវើករបស់ទីក្រុងឡូវែល សាលាក្រុងឡូវែលបោះទុនវិនិយោគលើកម្មវិធី

ដែលមាននិរន្តរភាពនានា ដើម្បីជួយដល់ពលរដ្ឋទីក្រុងឡូវែល ដែលមិនសូវមានគេគិតគូរ ឲ្យងើបឡើងវិញពីវិបត្តិ។

- ➢ ***ការអភិវឌ្ឍសេដ្ឋកិច្ច និងការស្តារឡើងវិញ។*** ការវិនិយោគនៃច្បាប់ ARPA នេះនឹងជួយទ្រទ្រង់អាជីវកម្មខ្នាតតូច ដោយជួយពួកគេក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ ដែលបណ្តាលមកពីជំងឺរាលដាលជាសាកល និងដាក់ទុនវិនិយោគលើការបង្ការជំងឺកូវីដ-១៩ និងយុទ្ធវិធីកាត់បន្ថយផលប៉ះពាល់ ព្រមទាំងដើម្បីផ្តល់ជំនួយបច្ចេកទេសផង។ សាលាក្រុងឡូវែលមានកញ្ចប់ថវិកាជំនួយជាច្រើន រួមទាំងថវិកាជំនួយមនុស្សធម៌ និងកម្មវិធីពិគ្រោះយោបល់ ដើម្បីជួយអាជីវកម្ម ឲ្យងើបឡើងវិញពីការធ្លាក់ចុះដោយសារវិបត្តិនោះ។ ចំណុចអាទិភាព នឹងត្រូវដាក់ចេញក្នុងការពន្លឿនការងើបឡើងវិញផ្នែកទេសចរណ៍ ការធ្វើដំណើរ និងវិស័យបដិសណ្ឋារកិច្ច ដោយជួយទ្រទ្រង់ឧស្សាហកម្ម ដែលរងផលប៉ះពាល់ខ្លាំង ដោយសារគ្រោះអាសន្ននៃជំងឺកូវីដ-១៩ និងឥឡូវនេះកំពុងចាប់ផ្តើមដោះស្រាយ។
- ➢ ***គម្រោងសុខភាពសាធារណៈ: ការបង់ធនលាភ និងអនុលោមភាព។*** ទីក្រុងឡូវែលនឹងបន្តដោះស្រាយបញ្ហាជំងឺកូវីដ-១៩ និងបញ្ហាសុខភាពសាធារណៈឯទៀត ព្រមទាំងកាត់បន្ថយផលប៉ះពាល់របស់វា និងដាក់ឲ្យដំណើរការផ្នែកនៃកម្មវិធីផ្តល់មូលនិធិជាច្រើន ដោយប្រើប្រាស់កញ្ចប់ថវិកាជាតិឲ្យមានតុល្យភាព។ ការបង់ប្រាក់ធនលាភនេះ នឹងត្រូវទូទាត់ដល់និយោជិតរបស់សាលាក្រុងទាំងឡាយណា ដែលត្រូវទទួលបានប្រាក់នេះ ព្រោះពួកគាត់បានធ្វើការក្នុងកន្លែងដែលប្រឈមជាសាធារណៈ ក្នុងអំឡុងនៃការរីករាលនៃជំងឺកូវីដ-១៩។

## ប្រភេទនៃថវិកាជំនួយ ARPA ដែលមាននៅទូទាំងក្រុងឡូវែល

ការផ្តល់មូលនិធិ ARPA នេះ នឹងត្រូវចែកចាយទៅគ្រប់ផ្នែកគោលដៅនៃគម្រោងដែលបានទទួលថវិកាជំនួយ ដោយផ្តោតលើការសម្រេចផល ដែលពាក់ព័ន្ធនឹងគោលការណ៍ ប្រភេទ និងផ្នែកសំខាន់ៗដែលបានពិភាក្សានៅក្នុងទំព័រមុនៗ។ ស្របពេលដែលគម្រោងស្តារឡើងវិញ បន្តដំណើរទៅមុខ នឹងមានឱកាសទទួលបានថវិកាជំនួយផ្សេងៗ ដើម្បីដោះស្រាយចំណុចអាទិភាពផ្សេងៗ។ ឱកាសផ្តល់ថវិកាជំនួយនីមួយៗ នឹងត្រូវប្រកាសឲ្យដឹង ជាទម្រង់សំណើរកអ្នកអនុវត្តគម្រោង (RFP) ដែលក្នុងអំឡុងពេលនោះ ពាក្យសុំនឹងបើកឲ្យមាន ដើម្បីជួយដោះស្រាយសេចក្តីត្រូវការចាំបាច់ជាក់លាក់។ សំណើរកអ្នកអនុវត្តគម្រោងនីមួយៗ នឹងមានរយៈពេលកំណត់ច្បាស់លាស់របស់វា ដែលនៅក្នុងអំឡុងពេលនោះ ពាក្យសុំនឹងត្រូវដាក់ដើម្បីត្រួតពិនិត្យ

វាយតម្លៃ និងលទ្ធភាពនៃការផ្តល់ថវិកាជំនួយ។ ដោយសារការមានមូលនិធិនេះ នឹងចេះតែដំណើរការទៅមុខ និងផ្អែកលើចំណុចអាទិភាព សាលាក្រុងអាចជ្រើសរើសពិនិត្យឡើងវិញ និងពង្រីកឱកាសដេញថ្លៃគម្រោងដែលមានពីមុន ឬកែប្រែលំដាប់លំដោយនៃការមានមូលនិធិនោះ។

សូមកត់សម្គាល់៖ រាល់ការផ្តល់ថវិកាជំនួយ ARPA ទាំងអស់នឹងផ្តល់ជូនក្នុងទម្រង់នៃការទូទាត់សង់វិញតាមក្រោយ (លើកលែងតែមានកំណត់ផ្ទុយពីនេះ)។ ការចំណាយត្រូវតែធ្វើឡើងដោយអ្នកទទួលបានថវិកាជំនួយ និងត្រូវរៀបចំវិក្កយបត្រត្រឹមត្រូវ និងកាលណាទូលបានការយល់ព្រម ថ្លៃចំណាយទាំងនោះនឹងត្រូវទូទាត់សងវិញដោយសាលក្រុងឡូវែល។

សាលាក្រុងនឹងធ្វើការដោយម៉ត់ចត់ ដើម្បីធ្វើយ៉ាងណាឲ្យសហាគមន៍បានជ្រាបដំណឹងអំពីឱកាសដេញថ្លៃគម្រោងទាំងនេះ តាមរយៈគេហទំព័ររបស់សាលាក្រុង https://www.lowellma.gov/1574/American-Rescue-Plan-Act។

## និជ្ជភាពនៃដំណើរការផ្តល់មូលនិធិជំនួយនៃច្បាប់ ARPA

### ព័ត៌មានទូទៅអំពីដំណើរការ

1. ការផ្តល់មូលនិធិ ARPA នេះត្រូវបានចាត់ចែង ដើម្បីដោះស្រាយសេចក្តីត្រូវការចាំបាច់ក្នុងសហគមន៍។
2. ក្នុងពេលដែលគម្រោងស្តារឡើងវិញ ចេះតែដំណើរការទៅមុខ នឹងមានឱកាសផ្សេងៗសម្រាប់ការផ្តល់មូលនិធិជំនួយនេះ។
3. ព័ត៌មានអំពីសំណើសុំដេញថ្លៃគម្រោង ការដាក់ពាក្យសុំមូលនិធិជំនួយ ARPA និងការប្រែប្រួលកាលវិភាគ ឬព័ត៌មានថ្មីៗចុងក្រោយ មាននៅគេហទំព័រនៃកម្មវិធីថវិកាជំនួយ ARPA របស់សាលាក្រុងឡូវែល៖ https://www.lowellma.gov/1574/American-Rescue-Plan-Act។
4. អង្គភាពដែលត្រូវលក្ខខណ្ឌ អាចដាក់ពាក្យសុំដេញថ្លៃគម្រោងច្រើនបាន។
5. ស្របពេលដែលអង្គភាពដែលត្រូវលក្ខខណ្ឌ អាចដាក់ពាក្យសុំដេញថ្លៃគម្រោង ARPA បានច្រើនយ៉ាងណាក៏ដោយ ក៏ដើម្បីការពិចារណាសំណើសុំដេញថ្លៃគម្រោងតែមួយ សូម **កុំបញ្ចូលគម្រោងរួមគ្នា**ទៅក្នុងពាក្យសុំតែមួយ។

### លក្ខខណ្ឌដាក់ពាក្យសុំ – តើនរណាអាចដាក់ពាក្យសុំមូលនិធិជំនួយនេះ?

1. រាល់ការទូទាត់សងវិញតាមក្រោយនៃកញ្ចប់ថវិកា ARPA នឹងត្រូវផ្តោតលើអង្គការមិនរកប្រាក់កម្រៃ និងអាជីវកម្មខ្នាតតូច។ ប៉ុន្តែ អាចនៅមានកម្មវិធីផ្សេងៗទៀត ដែលបង្កើតឡើងសម្រាប់ពលរដ្ឋផងដែរ។
2. សូមធ្វើយ៉ាងណាពិនិត្យព័ត៌មានលម្អិតនៃសំណើសុំដេញថ្លៃគម្រោងដែលលោកអ្នកចាប់អារម្មណ៍នោះ ដោយយកចិត្តទុកដាក់ នៅមុនដាក់ពាក្យ ព្រោះសំណើសុំដេញថ្លៃគម្រោងនីមួយ មានលក្ខខណ្ឌតម្រូវក្នុងការដាក់ពាក្យរបស់វារៀងៗខ្លួន។

### ពេលវេលា – តើអង្គាល់ទើពាក្យសុំថវិកាជំនួយ ARPA នេះត្រូវគេទទួលយក?

1. ឱកាសផ្តល់មូលនិធិជំនួយនីមួយៗ នឹងត្រូវប្រកាសជាទម្រង់សំណើរកអ្នកដេញថ្លៃគម្រោង (RFP)។
2. សំណើរកអ្នកដេញថ្លៃគម្រោងនីមួយៗ នឹងមានពាក្យសុំជំនួយថវិកា ARPA ខុសៗគ្នា។
3. សំណើរកអ្នកដេញថ្លៃគម្រោងនីមួយៗ នឹងមានកាលបរិច្ឆេទចាប់ផ្តើម និងបិទបញ្ចប់ ដែលនឹងមានរៀបរាប់នៅខាងលើបំផុតនៃសំណើរកអ្នកដេញថ្លៃគម្រោងនោះ។
   - ពាក្យសុំមូលនិធិជំនួយ ARPA នឹងអាចទទួលយកបានតែក្នុងចន្លោះកាលបរិច្ឆេទទាំងនេះប៉ុណ្ណោះ។

- ពាក្យសុំថវិកាជំនួយ ARPA ដែលដាក់ក្នុងពេលដែលដាក់ពាក្យស្នើសុំដេញថ្លៃគម្រោង បានបិទ/ចប់ (កាលបរិច្ឆេទកំណត់) នឹងមិនត្រូវបានទទួលយក ឬពិចារណានោះឡើយ។

## ការត្រៀមរៀបចំ – តើខ្ញុំត្រូវត្រៀមខ្លួនយ៉ាងដូចម្តេច ដើម្បីដាក់ពាក្យសុំនេះ?

1. ទាញយកឯកសារនៃសំណើដេញថ្លៃគម្រោង និងពិនិត្យមើលសេចក្តីសង្ខេបរបស់វា ដែលលោកអ្នកគ្រោងដាក់ពាក្យសុំ ជាមួយនឹងពាក្យសុំថវិកាជំនួយ ARPA ដែលពាក់ព័ន្ធ និងឯកសារបន្ថែមឯទៀត (ឧទាហរណ៍ ទម្រង់ IRS W-9 សំណើសុំលេខអត្តសញ្ញាណសម្គាល់អ្នកបង់ពន្ធ និងលិខិតបញ្ជាក់ឯកសារជំរឿនរបស់ក្រុងឡូវែលឆ្នាំ ២០២០ អំពីតំបន់ក្រីក្រ)។
   - សំណើសុំដេញថ្លៃគម្រោងនេះ នឹងមានបញ្ជាក់ច្បាស់អំពីទម្រង់ដែលចាំបាច់បន្ថែមផ្សេងទៀត ដែលទម្រង់ទាំងនោះ គួរតែមានដូចគ្នាក្នុងផ្នែកជាមួយសំណើសុំដេញថ្លៃគម្រោងនោះ។
2. សូមកុំភ្លេចពិនិត្យមើលផ្នែកនៃសំណើសុំដេញថ្លៃគម្រោង ក្រោមចំណងជើងថា "ការបញ្ជាក់អំពីពាក្យសុំ" សម្រាប់ព័ត៌មានសំខាន់ចាំបាច់ ក្នុងការដាក់ពាក្យសុំនេះ ដើម្បីចៀសវាងការពន្យាដំណើរការណាមួយ។
3. <u>អាជីវកម្ម និងអង្គការមិនរកប្រាក់កម្រៃ</u>៖ សូមបញ្ជាក់ថាលោកអ្នកបានដាក់ពាក្យសុំ និងទទួលបានលេខ SAM Unique Entity ID (UEI#)[1]។
   - **គ្មានការផ្តល់ថវិកាជំនួយណាមួយ នឹងត្រូវផ្តល់ជូនអង្គភាពទាំងនេះ ដោយគ្មាន SAM# នោះឡើយ។**
   - រដ្ឋាភិបាលជាតិ បានបង្កើតប្រព័ន្ធសម្រាប់ការគ្រប់គ្រងការផ្តល់គម្រោង (SAM) ដែលមជ្ឈមណ្ឌលកណ្តាលសម្រាប់រក្សាទុកឯកសារថ្នាក់ជាតិមួយ សម្រាប់អតិថិជនទាំងអស់ ដែលធ្វើអាជីវកម្មជាមួយរដ្ឋាភិបាលជាតិ រួមទាំងការផ្តល់កិច្ចសន្យា និងការទទួលបានថវិកាជំនួយផង។ ការចុះបញ្ជី SAM នេះ គឺធ្វើដោយឥតគិតថ្លៃ និងអាចរកបាននៅ http://sam.gov។
4. សំណួរ ឬជំនួយពាក់ព័ន្ធនឹងការដាក់ពាក្យនេះ គួរសួរទៅក្រុម ARPA តាមអ៊ីម៉េល៖ ARPA@lowellma.gov ឬតាមរយៈទូរស័ព្ទ៖ (978) 674-4043

## ការដាក់ពាក្យសុំ - បំពេញ និងដាក់ពាក្យសុំថវិកាជំនួយ ARPA ដើម្បីឱ្យត្រួតពិនិត្យ[2]

1. ពាក្យសុំថវិកាជំនួយ ARPA (និងទម្រង់បន្ថែមណាមួយ) គឺតម្រូវឲ្យទាញយកពីគេហទំព័រ ដើម្បីយកមកបំពេញលើកុំព្យូទ័រ ឬបោះពុម្ពវាចេញ និងបំពេញដោយដៃ។

[1] លេខ SAM UEI# ដាក់ជំនួសលេខ DUNS ដែលប្រើពីមុន ដែលជាលក្ខខណ្ឌតម្រូវរបស់រដ្ឋាភិបាលជាតិ សម្រាប់ការផ្តល់ថវិកាជំនួយសម្រាប់គម្រោង។ ការចុះបញ្ជី SAM គឺត្រូវធ្វើដោយឥតគិតថ្លៃ និងត្រូវតែជាថ្មីរាល់ឆ្នាំ និងផ្តល់នូវជំនួយតាមរយៈសេវាអតិថិជនថ្នាក់ជាតិតាមលេខនេះ៖ 866-606-8220។

[2] ការដាក់ឯកសារមិនពេញលេញ អាចពន្យាដំណើរការពិនិត្យពាក្យសុំរបស់លោកអ្នក។

2. សូមបំពេញពាក្យសុំថវិកាជំនួយ ARPA នេះ
3. សូមបំពេញទម្រង់បន្ថែមណាមួយ ដូចដែលបានពិពណ៌នា/តម្រូវនៅក្នុង RFP។
4. ដាក់ឯកសារទាំងអស់ ទាំងយកទៅដាក់ផ្ទាល់ដៃ ឬតាមរយៈប៉ុស្តិ៍ប្រៃសនីយ៍ US Postal Service ដោយផ្ញើទៅ៖ City of Lowell ARPA Team, City Hall - 375 Merrimack St - Room 34, Lowell, MA 01852។

## ដំណើរការ - តើសាលាក្រុងនឹងពិនិត្យពាក្យសុំថវិកាជំនួយ ARPA របស់លោកអ្នកដោយរបៀបណា?

1. កាលណាលោកអ្នកបានទទួលពាក្យសុំថវិកាជំនួយ ARPA របស់លោកអ្នកនោះគឺដំណើរការនៃការពិនិត្យពាក្យសុំនោះចាប់ផ្តើមហើយ។
2. ក្នុងពេលលក្ខខណ្ឌនៃការវាយតម្លៃ អាចប្លែកគ្នាទៅតាមសំណើសុំដេញថ្លៃគម្រោង ជាការសំខាន់ដែលសំណើនោះ ត្រូវដោះស្រាយគោលដៅ ប្រភេទ និងផ្នែកសំខាន់ៗមួយចំនួន ដែលច្បាប់ ARPA ចង់ឲ្យដោះស្រាយ។
3. គោលបំណងរបស់សាលាក្រុង គឺការសម្រេចលើពាក្យសុំថវិកាជំនួយនេះ ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ មិនថានៅថ្ងៃចុងបញ្ចប់នៃការដាក់ពាក្យសុំ ឬ (ពាក្យសុំដែលគ្មានកាលកំណត់) នោះឡើយ គឺត្រូវធ្វើក្នុងរយៈពេល ៣០ថ្ងៃ ក្រោយបានទទួលពាក្យសុំនោះ។
    - ដោយសារដំណើរការពិនិត្យ អាស្រ័យលើកត្តាផ្សេងៗជាច្រើន សំណើសុំដេញថ្លៃគម្រោងដែលមានភាពស្មុគស្មាញ ឬពាក្យសុំដែលរាងស្មុគស្មាញ អាចត្រូវការពេលបន្ថែមដើម្បីពិនិត្យ។
    - កាលណាស្ថានភាពនេះកើតឡើង យើងនឹងទាក់ទងទៅអ្នកដាក់ពាក្យ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ការផ្តល់គម្រោង - តើសាលាក្រុងធ្វើយ៉ាងដូចម្តេច ក្នុងការផ្តល់គម្រោងតាមសំណើ?

1. កាលណាសេចក្តីសម្រេចអំពីការផ្តល់មូលនិធិត្រូវបានឯកភាព សាលាក្រុងនឹង
    - ឯកភាពលើគម្រោង/គំនិតផ្តួចផ្តើមរបស់លោកអ្នក ដែលពាក់ព័ន្ធនឹងសំណើសុំដេញថ្លៃគម្រោងជាក់លាក់នោះ។
    - ផ្តល់លេខកូដដល់លោកអ្នក ដើម្បីសម្គាល់គម្រោងកិច្ចសន្យាផ្តល់ថវិកាជំនួយ ARPA។
    - ផ្ញើកិច្ចសន្យាអំពីការផ្តល់គម្រោង ARPA នេះមួយច្បាប់ទៅជូនលោកអ្នក។

2. **សូមបញ្ជូនកិច្ចសន្យាដែលសាលាក្រុងផ្តល់គម្រោងជូនលោកអ្នកនោះមកវិញ ដោយមានចុះហត្ថលេខារបស់លោកអ្នក ដើម្បីបញ្ជាក់ថាលោកអ្នកបានទទួលយកគម្រោង ARPA ដែលផ្តល់ជូននោះ ដោយភ្ជាប់មកជាមួយនូវឯកសារតម្រូវណាមួយដែលមាន។**
3. កាលណាកិច្ចសន្យាផ្តល់គម្រោង ARPA នេះត្រូវបានបញ្ជូនត្រឡប់មកវិញរួច សាលាក្រុងនឹង៖
   - ដំណើរការ និងកំណត់លេខអតិថិជនឲ្យមួយ (Vendor Number)
   - ដំណើរការ និងចេញលេខបញ្ជាទិញ Purchase Order ឲ្យមួយទៅតាមទំហំនៃគម្រោងនោះ។
   - ផ្សព្វផ្សាយគំនិតផ្តួចផ្តើមនៃគម្រោងរបស់លោកអ្នក លើគេហទំព័រសាលាក្រុងអំពី ARPA នេះ។

## ការផ្តល់មូលនិធិ - តើសាលាក្រុងនឹងផ្តល់មូលនិធិសម្រាប់គម្រោងនេះដោយរបៀបណា?

1. រាល់មូលនិធិ ARPA គឺត្រូវទូទាត់<u>តាមទម្រង់នៃការទូទាត់សងវិញតាមក្រោយ</u>នេះ (លើកលែងតែមានចែងជាក់លាក់ផ្ទុយពីនេះ)។ រាល់ការចំណាយរបស់អ្នកទទួលបានថវិកាជំនួយ ត្រូវតែចាយជាមុនសិន និងត្រូវមានវិក្កយបត្រត្រឹមត្រូវ និងក្រោយពេលយល់ព្រម ប្រាក់នេះនឹងត្រូវទូទាត់ឲ្យវិញដោយសាលាក្រុងឡូវែល។
2. លេខអតិថិជន និងលេខបញ្ជាទិញ នឹងត្រូវការជាចាំបាច់ សម្រាប់រៀបចំវិក្កយបត្រ ឬបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការផ្តល់មូលនិធិនេះ។
3. លេខកិច្ចសន្យាផ្តល់គម្រោង ARPA នឹងត្រូវការជាចាំបាច់ សម្រាប់រាល់ការធ្វើបច្ចុប្បន្នភាពទាំងអស់សម្រាប់គម្រោងនេះ។
4. លោកអ្នក ឬអង្គការរបស់លោកអ្នក ត្រូវចេញវិក្កយបត្រទៅសាលាក្រុងឡូវែល សម្រាប់ថវិកាជំនួយដែលត្រូវបានទូទាត់សងវិញតាមក្រោយនោះ។
5. វិក្កយបត្ររបស់លោកអ្នក ត្រូវរួមបញ្ចូល៖
   - លេខបញ្ជាទិញដែលចេញដោយសាលាក្រុងរបស់លោកអ្នក
   - លេខអតិថិជនដែលចេញដោយសាលាក្រុងរបស់លោកអ្នក
   - លេខកិច្ចសន្យាផ្តល់គម្រោង ARPA ដែលចេញដោយសាលាក្រុងរបស់លោកអ្នក
   - លេខវិក្កយបត្រ
   - កាលបរិច្ឆេទវិក្កយបត្រ
   - ពិពណ៌នាអំពីទំនិញ/សេវាដែលត្រូវចេញវិក្កយបត្រនោះ
   - តម្លៃគិតជាដុល្លារសម្រាប់វិក្កយបត្រ
6. សាលាក្រុងនឹងពិនិត្យមើលវិក្កយបត្រនោះ និងស្នើសុំព័ត៌មានបន្ថែមបើចាំបាច់។

7. មានវិក្កយបត្រនោះត្រូវបានឯកភាព នោះវាត្រូវដាក់ទៅដើម្បីដំណើរការ និងទូទាត់ប្រាក់។
8. ក្នុងករណីភាគច្រើន សាលាក្រុងនឹងចេញជាសែក ដែលត្រូវផ្ញើតាមប្រៃសនីយ៍ ក្នុងរយៈពេល ១០ថ្ងៃ ក្រោយវិក្កយបត្រត្រូវបានឯកភាពរួច។
    - រាល់មូលនិធិទាំងអស់ ត្រូវចេញដោយសែកដែលបោះពុម្ព និងផ្ញើជូនទៅអាសយដ្ឋានដូចដែលមានចុះក្នុងបញ្ជីលើទម្រង់ IRS W-9។ សាលាក្រុងឡូវែល **នឹងមិន** ផ្ញើប្រាក់ទូទាត់ណាមួយនៃមូលនិធិតាមប្រព័ន្ធផ្ទេរប្រាក់បែបអេឡិចត្រូនិកនោះឡើយ។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមពីណា?

សូមមើល**គេហទំព័ររបស់សាលាក្រុងឡូវែល អំពីកម្មវិធី ARPA** នេះ ដើម្បីអានព័ត៌មានលម្អិតអំពីសំណើសុំដេញថ្លៃគម្រោង ពាក្យសុំថវិកាជំនួយ ARPA និងការកែប្រែកាលវិភាគ ឬព័ត៌មានថ្មីៗចុងក្រោយ។ ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងច្បាប់ស្តីពីការសង្គ្រោះពលរដ្ឋអាមេរិកនេះ មាននៅទីនេះ៖

https://www.lowellma.gov/1574/American-Rescue-Plan-Act